មេរៀនទី ២

# អនុគមន៍ទូទៅ

## Common Function

**ម៉េង ហាន់**

គ្រូបង្រៀនកម្រិតឧត្តម

# MENG HANN

**Video Creator @ReanComputer101 Youtube Channel**

Rean Computer 101

## 1200+ YouTube Videos

- Tech Tutorials
- Tips & Tricks
- Software Guides
- Productivity & More

Windows | MS Word | MS Excel | PowerPoint | Tips & Tricks

Website
**www.menghann.com**
Sharing knowledge. Creating value.

**100+ Free Online Tools**
**toolkh.rean.me**
PDF Tools • Image Tools • Data Tools
Converters • SEO Tools • and more...

**Free Khmer Typing + English Typing**
**typinghero.rean.me**
Typing Hero – Practice • Improve • Challenge

**1200+**
YouTube Videos

**3+**
Web Projects

**Helping**
Thousands of Learners




Empowering learners through quality content & free digital tools.

## មេរៀននេះយើងនឹងសិក្សាពី៖

- រូបមន្ត Excel (Sum, Min, Max, Average)
- រូបមន្ត IF និង Rank
- រូបមន្ត Count, CountA
- រូបមន្ត Concat, Concatenate, &
- របៀប Copy Paste Special
- បំបែកអក្សរតាម Text-to-Columns
- បំបែកឈ្មោះពេញឬញែក លឿនតាម Flash Fill

# អនុគមន៍ Basic Function

ឧទាហរណ៍យើងមានតារាងដូចខាងក្រោម ដែលត្រូវធ្វើការគណនារក

- ពិន្ទុសរុបនៃមុខវិជ្ជាទាំងអស់
- ពិន្ទុតូចបំផុតរបស់សិស្សម្នាក់ និង ពិន្ទុធំបំផុតរបស់សិស្សម្នាក់
- ពិន្ទុមធ្យមភាគ ជាដើម

| ល.រ | ត្រកូល | នាមខ្លួន | ភេទ | ខ្មែរ | អង់គ្លេស | កុំព្យូទ័រ | គណិត |
|---|---|---|---|---|---|---|---|
| 1 | ជា | សុខា | ប្រុស | 10 | 6 | 8 | 9 |
| 2 | គឹម | វណ្ណៈ | ប្រុស | 9 | 5 | 5 | 4 |
| 3 | លឹម | ស្រីនាង | ស្រី | 8 | 4 | 5 | 6 |
| 4 | ម៉េង | សុវណ្ណារិទ្ធិ | ប្រុស | 9 | 6 | 6 | 7 |
| 5 | ស្រ៊ុន | សុភាព | ប្រុស | 7 | 7 | 8 | 5 |

# រូបមន្ត SUM

SUM ត្រូវបានប្រើសម្រាប់គណនាផលបូកនៃតម្លៃជាច្រើន

=SUM(number1, [number2],...)
=SUM(start_cell : end_cell)

ឧទាហរណ៍ គណនាប្រាក់បៀវត្ស និងប្រាក់រង្វាន់សរុបនៃបុគ្គលិកម្នាក់ៗ ក្នុងតារាងខាងក្រោម៖

D3 =SUM(B3,C3)

| | A | B | C | D |
|---|---|---|---|---|
| 1 | **គណនាប្រាក់បៀវត្ស និងប្រាក់រង្វាន់សរុប** | | | |
| 2 | **ឈ្មោះបុគ្គលិក** | **ប្រាក់ខែ($)** | **ប្រាក់រង្វាន់($)** | **ប្រាក់សរុប($)** |
| 3 | Dara | 500 | 50 | =SUM(B3,C3) |
| 4 | Sopha | 600 | 60 | |
| 5 | Vannak | 750 | 80 | |
| 6 | Lina | 550 | 40 | |
| 7 | Rina | 650 | 70 | |

Dara: =SUM(B3, C3)
Sophea: =SUM(B4, C4)
ឬ
Dara: =SUM(B3:C3)
Sophea: =SUM(B4:C4)

# អនុគមន៍ Basic Function

| Name | Formula | Meaning |
|---|---|---|
| Minimum | =**min**(number1, [number2],..)<br>=**min**(start_cell : end_cell) | រកលេខតូចបំផុត |
| Maximum | =**max**(number1, [number2],..)<br>=**max**(start_cell : end_cell) | រកលេខធំបំផុត |
| Average | =**average**(number1, [number2],..)<br>=**average** (start_cell : end_cell) | រកតម្លៃមធ្យម |
| Sum | =**sum**(number1, [number2],..)<br>=**sum**(start_cell : end_cell) | រកតម្លៃសរុប |
| Count | =**count**(value1, [value2],..) | រាប់ចំនួនតម្លៃ (លេខ) |
| Counta | =**counta**(value1, [value2],..) | រាប់ចំនួនតម្លៃ (លេខ ឬអក្សរ) |

ឧទាហរណ៍យើងមានតារាងដូចខាងក្រោម ចូរគណនារក

| | A | B | C | D | E | F | G | H | I | J | K | L | M |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2 | ល.រ | ត្រកូល | នាមខ្លួន | ខ្មែរ | អង់គ្លេស | កុំព្យូទ័រ | គណិត | សរុប | តិចបំផុត | ច្រើនបំផុត | មធ្យមភាគ | ជាប់ធ្លាក់ | ចំណាត់ថ្នាក់ |
| 3 | 1 | ជា | សុខា | 10 | 6 | 8 | 9 | | | | | | |
| 4 | 2 | គឹម | វណ្ណៈ | 9 | 5 | 5 | 4 | | | | | | |
| 5 | 3 | លឹម | ស្រីនាង | 8 | 4 | 5 | 6 | | | | | | |
| 6 | 4 | ម៉េង | សុវណ្ណារិទ្ធិ | 9 | 6 | 6 | 7 | | | | | | |
| 7 | 5 | ស្រ៊ុន | សុភាព | 7 | 7 | 8 | 5 | | | | | | |

1. ផលបូកសរុបនៃមុខវិជ្ជាទាំងអស់
2. ពិន្ទុតិចបំផុតនៃសិស្សម្នាក់ៗក្នុងចំណោមមុខវិជ្ជាទាំងអស់
3. ពិន្ទុធំបំផុតនៃសិស្សម្នាក់ៗក្នុងចំណោមមុខវិជ្ជាទាំងអស់
4. ពិន្ទុមធ្យមភាគនៃសិស្សម្នាក់ៗ
5. លទ្ធផលជាប់ធ្លាក់ (ពិន្ទុ >=20 ជាប់, ពិន្ទុ <20 ធ្លាក់)
6. ចំណាត់ថ្នាក់នៃសិស្សម្នាក់ៗ

# រូបមន្ត IF

ផ្តលទូវតម្លៃដោយផ្អែកលើលក្ខខណ្ឌបើពិតបង្ហាញតម្លៃផ្អែកពិត បើមិនពិត បង្ហាញតម្លៃផ្អែកមិនពិត

**=IF(logical_test, value_if_true, value_if_false)**

ការប្រើប្រាស់សញ្ញាប្រៀបធៀប

| Meaning | Symbol | compare | True/False |
|---|---|---|---|
| តូចជាង | < | 1<2 | ពិត |
| តូចជាងឬស្មើរ | <= | 2<=2 | ពិត |
| ធំជាង | > | 1>2 | មិនពិត |
| ធំជាងឬស្មើរ | >= | 2>=1 | ពិត |
| ស្មើរ | = | 1=1 | ពិត |

# ឧទាហរណ៍

ចូរប្រើ IF បង្ហាញពាក្យ “ជាប់”បើសរុបធំជាងឬស្មើ 50 និង “ធ្លាក់” បើសរុបតិចជាង 50

| | A | B | C | D | E |
|---|---|---|---|---|---|
| 2 | ល.រ | ត្រកូល | នាមខ្លួន | សរុប | ជាប់/ធ្លាក់ |
| 3 | 1 | ជា | សុខា | 80 | ជាប់ |
| 4 | 2 | គឹម | វណ្ណៈ | 45 | |
| 5 | 3 | លឹម | ស្រីនាង | 89 | |
| 6 | 4 | ម៉េង | សុវណ្ណារិទ្ធិ | 75 | |
| 7 | 5 | ស្រ៊ុន | សុភាព | 67 | |

=IF(D3 >=50,"ជាប់","ធ្លាក់")

=IF(D4 >=50,"ជាប់","ធ្លាក់")

# រូបមន្ត Rank

គណនារកចំណាត់ថ្នាក់ លេខ១ លេខ២ ...

**= RANK (number, ref, [order])**

-number: តម្លៃលេខរបស់ទិន្នន័យនីមួយៗដែលត្រូវរកចំណាត់ថ្នាក់

-ref : តារាងទិន្នន័យទាំងអស់ដែលត្រូវយកមកប្រៀបធៀប

| | A | B | C | D | E |
|---|---|---|---|---|---|
| 2 | ល.រ | ត្រកូល | នាមខ្លួន | សរុប | ចំណាត់ថ្នាក់ |
| 3 | 1 | ជា | សុខា | 80 | 2 |
| 4 | 2 | គឹម | វណ្ណៈ | 45 | 5 |
| 5 | 3 | លឹម | ស្រីនាង | 89 | 1 |
| 6 | 4 | ម៉េង | សុវណ្ណារិទ្ធិ | 75 | 3 |
| 7 | 5 | ស្រ៊ុន | សុភាព | 67 | 4 |

=RANK(D3, D3:D7)

**=RANK(D3, $D$3:$D$7)**

# ប្រើប្រាស់រូបមន្ត Concat, Concatenate, &

ត្រូវបានប្រើដើម្បីតភ្ជាប់តម្លៃចូលគ្នា

| ល.រ | ត្រកូល | នាមខ្លួន | ឈ្មោះពេញ |
|---|---|---|---|
| 1 | ជា | សុខា | ជា សុខា |
| 2 | គឹម | វណ្ណៈ | |
| 3 | លឹម | ស្រីនាង | |
| 4 | ម៉េង | សុវណ្ណារិទ្ធិ | |
| 5 | ស្រ៊ុន | សុភាព | |

រូបមន្តទូទៅ: =concat(value1, value2, ...) for Excel 2016 or newer version

=concatenate (value1, value2, ...)

=value1 & value2 & .....

# ញែកតម្លៃជាមួយ Text to Column

| តម្លៃ | ឈ្មោះ | ភេទ | លេខទូរសព្ទ |
|---|---|---|---|
| សុខ សុភា, ស្រី, 012345678 | | | |
| ជា វិសាល, ប្រុស, 098765432 | | | |
| លី សុវណ្ណា, ស្រី, 097111222 | | | |




ជ្រើសរើសទិន្នន័យ (A2:A4)

ទៅកាន់ផ្ទាំង Data Menu ចុច **Text to Columns**

ជ្រើស Delimited → ចុច Next.នៅក្នុង Delimiters, ត្រួតពិនិត្យ

Comma → ចុច Next.ជ្រើសទីតាំងដាក់ទិន្នន័យថ្មី (ឧ. B2).ចុច Finish.

# បំបែកឈ្មោះពេញឬញែក លឿនតាម Flash Fill

ការផ្គុំតម្លៃចូលគ្នា ឬ ញែកតម្លៃចេញពីគ្នា ដំបូងត្រូវវាយតម្លៃជាលទ្ធផលដែលយើងចងបាន ហើយចាប់អូសចុះក្រោម រួចជ្រើសរើសយក Flash Fill ។ *(មានលើ Excel ២០១៣ ឡើងឬ Excel 365)*

| ល.រ | ត្រកូល | នាមខ្លួន | ឈ្មោះពេញ | ត្រកូល |
|---|---|---|---|---|
| 1 | ជា | សុខា | ជា សុខា | ជា |
| 2 | គឹម | វណ្ណៈ | គឹម វណ្ណៈ | គឹម |
| 3 | លឹម | ស្រីនាង | លឹម ស្រីនាង | លឹម |
| 4 | ម៉េង | សុវណ្ណារិទ្ធិ | ម៉េង សុវណ្ណារិទ្ធិ | ម៉េង |
| 5 | ស្រ៊ុន | សុភាព | ស្រ៊ុន សុភាព | ស្រ៊ុន |



# ប្រើ Paste as Value

ប្រសិនបើអ្នកចង់ copy តម្លៃកន្លែងដែលមានរូបមន្ត ហើយចង់យកតែតម្លៃដោយមិនមានជាប់រូបមន្ត សាកវិធីសាស្ត្រនេះ

បន្ទាប់ពី Copy រួច ចុច Mouse ស្តាំត្រង់ទីតាំង

ចង់ Paste រួចជ្រើសរើស Value ក្នុង Paste Options (មើលរូប)

